អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះសាលាដំបូងប្រកាសរបៀបវារៈសម្រាប់សវនាការបឋមនៃសំណុំរឿង ០០២

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមប្រកាសថា សវនាការបឋមនៃសំណុំរឿង ០០២ នឹងប្រព្រឹត្តទៅ ពីម៉ោង ៩:00 ព្រឹក ដល់ម៉ោង ០៤:00 រសៀល រៀងរាល់ថ្ងៃ ចាប់ពីថ្ងៃទី ២៧-៣០ ខែមិថុនា ឆ្នាំ២០១១ ហើយនឹងមានទទ្បីករណ៍ផ្ទាល់មាត់ពីភាគីដែលពាក់ព័ន្ធទៅលើអញ្ញត្រកម្មបឋម។

**របៀបវារៈនៃសវនាការ**

| កាលបរិច្ឆេទ | ម៉ោង | សវនាការ |
|---|---|---|
| ច័ន្ទ ២៧ មិថុនា | ៩:00 -១៦:00 | **១) សេចក្តីប្រកាសបញ្ជីឈ្មោះសាក្សីបណ្តោះអាសន្ន** (សម្រាប់ដំណាក់កាលដំបូងនៃការជំនុំជម្រះ)<br>**២) អញ្ញត្រកម្មអំពីគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ** - យ៉ាងយូរបំផុតរយៈពេល២ម៉ោងនិង៣០នាទី (ទទ្បីករណ៍ផ្ទាល់មាត់ដោយសហមេធាវីការពារក្តីឲ្យលោក អៀង សារី, សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី)<br>**៣) អញ្ញត្រកម្មអំពីការលើកលែងទោស/អនុគ្រោះទោស** - រយៈពេល២ម៉ោងនិង៣០នាទី (ទទ្បីករណ៍ផ្ទាល់មាត់ដោយសហមេធាវីការពារក្តីឲ្យលោក អៀង សារី, សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី) |
| អង្គារ ២៨ មិថុនា | ៩:00 -១៦:00 | **៤) អញ្ញត្រកម្មអំពីអាជ្ញាយុកាលទាក់ទិននឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ** - រយៈពេល២ម៉ោងនិង៣០នាទី (ទទ្បីករណ៍ផ្ទាល់មាត់ដោយសហមេធាវីការពារក្តីឲ្យលោក អៀង សារី, សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី)<br>**៥) អញ្ញត្រកម្មអំពីអាជ្ញាយុកាលនៃបទល្មើសទាក់ទិនទៅនឹងបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៥៦** - រយៈពេល៤ម៉ោងនិង៣០នាទី (ទទ្បីករណ៍ផ្ទាល់មាត់ដោយក្រុមមេធាវីការពារក្តីទាំងអស់, សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី) |

| | | |
|---|---|---|
| ពុធ ២៩ មិថុនា | ៩:០០ -១៦:០០ | **៦) អញ្ញត្រកម្មអំពីអាជ្ញាយុកាលនៃបទល្មើសទាក់ទិននឹងបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៥៦** - សវនការបន្តពីថ្ងៃទី ២៨ មិថុនា<br>**៧) ការបញ្ជាក់បឋមអំពីខ្លឹមសារនៃសំណងរដ្ឋប្បវេណី** ដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី - យ៉ាងយូរបំផុតរយៈពេល១ម៉ោង |
| ព្រហស្បតិ៍ ៣០ មិថុនា | ៩:០០ -១៦:០០ | ៨) ទឡ្ហីករណ៍ផ្ទាល់មាត់ពាក់ព័ន្ធនឹងការជំទាស់នានា ប្រសិនបើមាន ទាក់ទិននឹងបញ្ជីឈ្មោះសាក្សីដែលបានស្នើឡើង |

ព័ត៌មានលម្អិតអំពីរបៀបវារៈនៃសវនាការបឋម សូមទាញយកពី:
http://www.eccc.gov.kh/document/court/14853

បន្ទាប់ពីសវនាការបឋម អង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចជាចុងក្រោយទៅលើបញ្ជីឈ្មោះសាក្សីនិងអ្នកជំនាញសម្រាប់ដំណាក់កាលដំបូងនៃការជំនុំជម្រះលើអង្គសេចក្តី និងកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តី។

ជាងនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងអាចនឹងរៀបចំសវនាការមួយទៀតនៅខែសីហា ឆ្នាំ២០១១ មុនការចាប់ផ្តើមសវនាការលើអង្គសេចក្តី។ សេចក្តីលម្អិតនៃសវនាការបន្តនឹងជូនដំណឹងតាមពេលវេលាដែលបានកំណត់។

**សេចក្តីណែនាំសម្រាប់អ្នកចូលរួមស្តាប់សវនាការ**

សវនាការបឋមនៅខែមិថុនាគឺបើកទូលាយសម្រាប់សាធារណជនទូទៅ។ ដើម្បីរក្សាសណ្តាប់ធ្នាប់និងរបៀបរៀបរយនៅក្នុងអំឡុងពេលសវនាការ អ.វ.ត.ក បានបែងចែកកន្លែងអង្គុយសម្រាប់កន្លែងទាំង៤៨២នៅក្នុងសាលសវនាការ។

កន្លែងអង្គុយចំនួន៤០ ត្រៀមសម្រាប់សាធារណជនដែលមកជាលក្ខណៈបុគ្គល (ពុំចាំបាច់ចុះឈ្មោះជាមុន)។ កន្លែងអង្គុយចំនួន ១០០ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ហើយកន្លែងអង្គុយចំនួន ២២០ទៀត សម្រាប់ប្រជាជនមកពីតាមបណ្តាខេត្តដែលមកចូលរួមតាមរយៈផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក។ កន្លែងអង្គុយមួយចំនួនទៀតនឹងត្រូវបានត្រៀមសម្រាប់អង្គទូត មន្ត្រីរាជរដ្ឋាភិបាល អ្នកស្រាវជ្រាវជាន់ខ្ពស់ និងតំណាងអង្គការក្រៅរដ្ឋាភិបាលដែលជាដៃគូររបស់ អ.វ.ត.ក។ អ្នកចូលរួមត្រូវតែចុះឈ្មោះជាមុនតាមរយៈ pas@eccc.gov.kh។ កាលបរិច្ឆេទចុងក្រោយបំផុតសម្រាប់ការចុះឈ្មោះគឺ ថ្ងៃច័ន្ទ ទី២០ ខែមិថុនា ឆ្នាំ២០១១។

អ្នកចូលរួមគួរតែមកដល់ អ.វ.ត.ក ចន្លោះពីម៉ោង ៧:៣០ ដល់ម៉ោង ៨:០០ ព្រឹក ដើម្បីទុកពេលវេលាសមស្របសម្រាប់ការចែកសំបុត្រចូលនិងការត្រួតពិនិត្យសន្តិសុខ។ អ.វ.ត.ក នឹងបិទច្រកចូលទៅកាន់សាលសវនាការនៅម៉ោង ៨:៤៥ ឬនៅពេលដែលសាលសវនាការមានមនុស្សអង្គុយពេញ។

ដើម្បីចូលក្នុងសាលសវនាការ អ្នកចូលរួមត្រូវតែបង្ហាញប័ណ្ណសម្គាល់ខ្លួនដែលមានបិទរូបថតដល់សន្តិសុខនៅមាត់ទ្វារខាងក្រៅ។ សូមរំឭកថា អ្នកដែលមានអាយុក្រោម១៦ឆ្នាំនឹងមិនត្រូវបានអនុញ្ញាតឲ្យចូលរួមឡើយ ហើយអ្នកដែលមានអាយុចន្លោះពី១៦ដល់១៨ឆ្នាំ អាចចូលបានលុះត្រាតែមានមនុស្សចាស់មកជាមួយ។ សាធារណជនត្រូវតែមានអាកប្បកិរិយាថ្លៃថ្នូរនិងសមរម្យគ្រប់ពេលវេលា និងត្រូវមានសម្លៀកបំពាក់សមរម្យ។ មិនអនុញ្ញាតឲ្យយកទូរស័ព្ទដៃ កាបូបធំៗ អាហារឬភេសជ្ជៈ ចូលក្នុងសាលសវនាការឡើយ។

អ.វ.ត.ក មានទីតាំងនៅសង្កាត់ចោមចៅ ចម្ងាយ១៦ គីឡូម៉ែត្រពីរាជធានីភ្នំពេញ ខាងឆ្វេងផ្លូវជាតិលេខ៤។ សាធារណជននិងតំណាងសារព័ត៌មានសូមអញ្ជើញចូលតាមច្រកសម្រាប់ភ្ញៀវដែលស្ថិតនៅផ្នែកខាងកើតនៃ អ.វ.ត.ក។ អ.វ.ត.ក មានទីធ្លាសម្រាប់ភ្ញៀវចតយានយន្ត។

## សម្រាប់អ្នកតំណាងសារព័ត៌មាន

តំណាងសារព័ត៌មានដែលមានបំណងចូលរួមតាមដានសវនាការបឋមថ្ងៃទី ២៧-៣០ ខែមិថុនា ត្រូវតែមានប័ណ្ណព័ត៌មាន និងចុះឈ្មោះជាមុន។ តំណាងសារព័ត៌មានត្រូវតែបំពេញនីតិវិធីដូចខាងក្រោម៖

ក) អ្នកសារព័ត៌មានដែលកំពុងកាន់ប័ណ្ណព័ត៌មានមានសុពលភាពជាផ្លូវការរបស់អ.វ.ត.ក ត្រូវចុះឈ្មោះនៅផ្នែកកិច្ចការសាធារណៈតាមរយៈការផ្ញើសារអេឡិចត្រូនិកទៅកាន់ PAS@ECCC.GOV.KH។

ខ) អ្នកសារព័ត៌មានដែលមានប័ណ្ណព័ត៌មានជាផ្លូវការរបស់ អ.វ.ត.ក ប៉ុន្តែផុតកំណត់ ត្រូវបំពេញទម្រង់បែបបទសុំប័ណ្ណព័ត៌មានសាជាថ្មី (ដោយមានចុះហត្ថលេខាផង) និងផ្ញើមកជាមួយនឹងសំណើសុំចុះឈ្មោះតាមរយៈសារអេឡិចត្រូនិក PAS@ECCC.GOV.KH ។ សូមកុំភ្លេចបញ្ជាក់លេខប័ណ្ណចាស់ដែលផុតកំណត់។

គ) អ្នកសារព័ត៌មានដែលមិនទាន់មានប័ណ្ណព័ត៌មានដែលចេញដោយ អ.វ.ត.ក ត្រូវបំពេញទម្រង់បែបបទសុំប័ណ្ណសារព័ត៌មាន និងភ្ជាប់រូបថតទម្រង់ jpg មួយសន្លឹក ផ្ញើមកជាមួយសំណើសុំចុះឈ្មោះតាមរយៈសារអេឡិចត្រូនិក PAS@ECCC.GOV.KH។

ទម្រង់បែបបទសម្រាប់សុំប័ណ្ណព័ត៌មាន អាចទាញយកបានពីគេហទំព័ររបស់ អ.វ.ត.ក: http://www.eccc.gov.kh/sites/default/files/ECCC_Accreditation_Media_Application_Form.doc.

អ.វ.ត.ក ត្រៀមបម្រុងកន្លែងអង្គុយចំនួន ៣០ កៅអី នៅក្នុងសាលសវនាការ សម្រាប់តំណាងសារព័ត៌មាន។ អាទិភាពនឹងត្រូវបានផ្តល់ជូនអ្នកសារព័ត៌មានខាងផ្នែកបោះពុម្ព។ តំណាងសារព័ត៌មានដទៃទៀតនឹងត្រូវរៀបចំជូនកន្លែងអង្គុយក្នុងបន្ទប់សារព័ត៌មាននៅជាន់ផ្ទាល់ដី។ តំណាងសារព័ត៌មានដែលមានបំណងទទួលបានកន្លែងអង្គុយក្នុងសាលសវនាការ ត្រូវផ្ញើពាក្យសុំកន្លែងអង្គុយយ៉ាងយូរបំផុតត្រឹមថ្ងៃច័ន្ទ ទី២០ ខែមិថុនា ឆ្នាំ២០១១។

**កាលបរិច្ឆេទចុងក្រោយសម្រាប់ការចុះឈ្មោះសុំប័ណ្ណព័ត៌មានគឺ៖ ថ្ងៃពុធ ទី២២ ខែមិថុនា ឆ្នាំ២០១១។**

សម្រាប់ព័ត៌មានបន្ថែម សូមមើលនៅ:

http://www.eccc.gov.kh/en/articles/media-advisory-initial-hearing

អ.វ.ត.ក នឹងអនុញ្ញាតឲ្យអ្នកសារព័ត៌មានមករៀបចំឧបករណ៍ថតចម្លងសំឡេងនិងថតវីដេអូជាមុន នៅថ្ងៃទី ២៥-២៦ ខែមិថុនា ឆ្នាំ២០១១។ ផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក នឹងរៀបចំសន្និសីទកាសែតមួយនៅវេលាម៉ោង ២:០០ រសៀលថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១១។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**ឌីម សុវណ្ណារុំ**
មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទដៃ: +៨៥៥(0) ១២ ៤៨៨ ០៩៤
ទូរសារ: +៨៥៥(0) ២៣ ២១៩ ៨៤១
សារអេឡិចត្រូនិក: dim.sovannarom@eccc.gov.kh

**យូកូ ម៉ៃដា**
មន្ត្រីកិច្ចការសាធារណៈ
ទូរស័ព្ទ: +៨៥៥(0) ២៣ ៨១៤ លេខបន្ត: ៦១៣៩
ទូរស័ព្ទដៃ: +៨៥៥ (0) ១២ ៤៨៨ ៣១៩
សារអេឡិកត្រូនិក: maeday@un.org

**ហ៊ុយ វណ្ណៈ**
មន្ត្រីកិច្ចការសាធារណៈ
ទូរស័ព្ទដៃ: +៨៥៥ (0) ១២ ៣៣៩ ៤២៧
ទូរសារ: +៨៥៥(0) ២៣ ២១៩ ៨៤១
សារអេឡិកត្រូនិក: huy.vannak@eccc.gov.kh